ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ........សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការកែសម្រួលការប្រើប្រាស់ប្រាក់រង្វាន់នៃចំណូលប្រមូលដោយ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ៨៦២ សហវ.ប្រក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិង ✓



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
St,92,Sangkat Wat Phnom, Khan Daun Penh, Phnom Penh, COMBODIA. Phone : 855-23-724 664 Fax: 855-23-427 798

ហិរញ្ញវត្ថុ ស្តីពីការប្រើប្រាស់ប្រាក់រង្វាន់នៃចំណូលប្រមូលដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

- យោងប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់គោលការណ៍ យន្តការ នីតិវិធី និងការត្រួតពិនិត្យសម្រាប់ការផ្តល់ការលើកទឹកចិត្ត ដោយប្រើប្រាស់ប្រាក់រង្វាន់របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងលិខិតលេខ ៣៤២៤ សហវ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការអនុញ្ញាតប្រើប្រាស់ថវិការង្វាន់ នៃចំណូលប្រមូលដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ប្រាក់រង្វាន់១%នៃចំណូលប្រមូលដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលត្រូវបានកំណត់តាមបញ្ញត្តិលិខិតលេខ ៣៤២៤ សហវ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកែសម្រួល និងកំណត់បែងចែកឡើងវិញដូចតទៅ÷

- ៦០%នៃប្រាក់រង្វាន់ សម្រាប់ឧបត្ថម្ភជីវភាពជូនមន្ត្រីរាជការគយនិងរដ្ឋាករទាំងឡាយណាដែលមកបំពេញការងារទៀងទាត់ ទៅតាមគោលការណ៍សមធម៌ ប្រកបដោយគុណភាព និងផលិតភាព។
- ១០%នៃប្រាក់រង្វាន់ សម្រាប់ឧបត្ថម្ភមុខងារជូនមន្ត្រីរាជការគយនិងរដ្ឋាករទាំងឡាយណាដែលបំពេញមុខងារពាក់ព័ន្ធនឹងការងារដឹកនាំ ការងារកែទម្រង់ ការងារសិក្សាស្រាវជ្រាវ ការងាររៀបចំច្បាប់និងគោលនយោបាយ ការងារជំនាញចាំបាច់ ការងារចូលរួមអនុវត្តគម្រោង និងការងារផ្សេងៗទៀត ព្រមទាំងការងារផ្តល់មតិប្រឹក្សាច្បាប់ជូនអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។
- ១៥%នៃប្រាក់រង្វាន់ សម្រាប់ចំណាយក្នុងការអភិវឌ្ឍស្ថាប័ន សាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការបំពាក់មធ្យោបាយប្រដេញ និងសម្ភារទូរគមនាគមន៍ តាមតម្រូវការចាំបាច់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាតាមបទបញ្ញត្តិជាធរមាន។
- ១០%នៃប្រាក់រង្វាន់ សម្រាប់លើកទឹកចិត្តដល់អង្គភាព និងមន្ត្រីគាំទ្រដទៃទៀតនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅតាមគោលការណ៍សមធម៌ និងគុណសម្បត្តិការងារ។
- ៥%នៃប្រាក់រង្វាន់ ត្រៀមបំរុងក្នុងបេឡាសមូហភាព សម្រាប់ជាប្រាក់រង្វាន់សមិទ្ធិកម្ម និងសម្រាប់ចំណាយលើការឧបត្ថម្ភមន្ត្រីរាជការគយនិងរដ្ឋាករកម្ពុជា និងមន្ត្រីជាប់កិច្ចសន្យាក្នុងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាដែលមានជួបប្រទះគ្រោះថ្នាក់ ឈឺថ្កាត់ ឬមហន្តរាយផ្សេងៗ ព្រមទាំងការចំណាយចាំបាច់ប្រហាក់ប្រហែល តាមការកំណត់របស់អគ្គនាយកគយនិងរដ្ឋាករកម្ពុជា។

**ប្រការ២.-**

ប្រាក់រង្វាន់៦០% សម្រាប់ឧបត្ថម្ភជីវភាព ដូចមានចែងក្នុងបញ្ញត្តិប្រការ១ នៃប្រកាសនេះ ត្រូវបានផ្តល់ ✓

ជូនមន្ត្រីរាជការគយនិងរដ្ឋាករកម្ពុជាប្រចាំខែ ទៅតាមមេគុណសមាមាត្រ ដូចមានចែងក្នុងបញ្ញត្តិប្រការ២ នៃប្រកាសលេខ ៨៦២ សហវ.ប្រក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចយោងខាងលើ។

ប្រាក់រង្វាន់១០% សម្រាប់ឧបត្ថម្ភមុខងារ ដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ ត្រូវបានផ្តល់ជូនមន្ត្រីរាជការគយនិងរដ្ឋាករកម្ពុជាប្រចាំខែ ទៅតាមមេគុណសមាមាត្រ ដូចមានចែងក្នុងបញ្ញត្តិប្រការ២ នៃប្រកាសលេខ ៨៦២ សហវ.ប្រក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចយោងខាងលើ។ ក្នុងករណីមានជំនាញពិសេសចាំបាច់ ដែលតម្រូវឱ្យមានការផ្តល់ប្រាក់ឧបត្ថម្ភមុខងារខ្ពស់ គណៈកម្មាធិការវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្ត អាចពិនិត្យនិងសម្រេចលើសំណើផ្តល់តាមមេគុណសមាមាត្រណាមួយ ក្នុងចំណោមមេគុណសមាមាត្រដែលបានកំណត់ខាងលើ។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវកសាងបញ្ជីឈ្មោះមន្ត្រីដែលត្រូវទទួលប្រាក់ឧបត្ថម្ភមុខងារសម្រាប់មួយត្រីមាសម្តងឱ្យបានទៀងទាត់ ដើម្បីជាមូលដ្ឋានក្នុងការបែងចែកប្រាក់រង្វាន់នេះ។

**ប្រការ៣.-**

យន្តការ នីតិវិធី និងការត្រួតពិនិត្យការផ្តល់ការលើកទឹកចិត្ត ត្រូវអនុវត្តតាមបញ្ញត្តិជំពូក៣ នៃប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដូចយោងខាងលើ។

**ប្រការ៤.-**

បញ្ញត្តិប្រការ២ នៃប្រកាសលេខ ៨៦២ សហវ.ប្រក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការប្រើប្រាស់ប្រាក់រង្វាន់នៃចំណូលប្រមូលដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៤

**រដ្ឋមន្ត្រី**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា "ដើម្បីជូនជ្រាប"
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ